**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

3

# សុន្ទរកថា

## ឯកឧត្តម កែ គឹមយ៉ាន ឧបនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង ជាតំណាងដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ថ្លែងក្នុងឱកាសប្រារព្ធទិវា ពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៣

**សាលសន្និសីទចតុមុខ ០១ ធ្នូ ២០១៣**

**"ឈានទៅរក គ្មានការឆ្លងថ្មី គ្មានការរើសអើង និងគ្មានការស្លាប់"**

- សូមគោរព គណៈអធិបតី
- សម្តេច ឯកឧត្តម លោកជំទាវ សមាជិក សមាជិកាព្រឹទ្ធសភា រដ្ឋសភា និង រាជរដ្ឋាភិបាល
- ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត រដ្ឋទូត តំណាងអង្គទូត លោក លោកស្រីជាភ្ញៀវជាតិ អន្តរជាតិ និងក្មួយៗសិស្សនិស្សិតទាំងអស់ជាទីរាប់អាន

ថ្ងៃនេះ ខ្ញុំមានមោទនភាពខ្ពស់ ដោយបានទទួលការចាត់តាំង ជាតំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ជាគណៈអធិបតី និង ចូលរួមជាមួយសកលលោក ប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ០១ធ្នូ ឆ្នាំ២០១៣ ដ៏មហោឡារិកនាពេលនេះ ។ នេះជាឱកាសមួយ ដែលរូបខ្ញុំផ្ទាល់បានសំដែងនូវការកោតសរសើរដ៏ជ្រាលជ្រៅ ជូនចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ ដែលបានខិតខំប្រឹងប្រែង ប្រកបដោយការប្តេជ្ញាចិត្តខ្ពស់ ធ្វើការងារប្រយុទ្ធនឹង

ជំងឺអេដស៍ប្រកបដោយជោគជ័យ តាមរយៈកាត់បន្ថយការចម្លងមេរោគអេដស៍ថ្មី ការបង្កើន អត្រាគ្របដណ្តប់ការថែទាំ និងព្យាបាល ជូនដល់អ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ រួមជាមួយនឹងការកាត់បន្ថយផលប៉ះពាល់ ដោយសារមេរោគអេដស៍ និងជំងឺអេដស៍ ទៅលើកុមារកំព្រា និង កុមារងាយរងគ្រោះ ប្រកបដោយប្រសិទ្ធភាពខ្ពស់ និង ប្រកបដោយក្តីសង្ឃឹមដ៏ពិតប្រាកដ ក្នុងការឈានទៅសំរេចបាន នូវគោលដៅអភិវឌ្ឍន៍សហស្សវត្ស និង គោលដៅបីសូន្យនាឆ្នាំ២០១៥-២០២០ខាងមុខនេះ ។

ឯកឧត្តម លោកជំទាវ លោក-លោកស្រី និង ក្មួយៗ ជាទីរាប់អាន!

វឌ្ឍនភាព ប្រសិទ្ធភាព និង សមិទ្ធផលប្រយុទ្ធនឹងជំងឺអេដស៍ ដែលកម្ពុជាទទួលបាននាពេលនេះ គឺជាភ័ស្តុតាងវិទ្យាសាស្ត្រមួយ យ៉ាងពិតប្រាកដ ដែលបញ្ជាក់ច្បាស់ថា ទស្សនៈវិស័យរបស់យើង ក្នុងការកសាងសង្គមមួយ ដែលគ្មានគ្រោះគំរាមកំហែង ពីមេរោគអេដស៍ និងជំងឺអេដស៍ គឺពិតជាអាចធ្វើបាន មានន័យថា កម្ពុជាអាចសំរេចបាន នូវគោលដៅបីសូន្យ ដែលកំណត់ដោយអង្គការសហប្រជាជាតិ នៅត្រឹមឆ្នាំ២០២០ ខាងមុខនេះ ។

តាមរយៈរបាយការណ៍អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានបង្ហាញយ៉ាងពិតប្រាកដថា កម្ពុជាបានកាត់បន្ថយការចម្លងមេរោគអេដស៍ថ្មី រហូតបានដល់ទៅ៥០% គិតចាប់តាំងពីឆ្នាំ២០១១ ហើយករណីឆ្លងមេរោគអេដស៍ថ្មី កំពុងតែធ្លាក់ចុះជាបន្តបន្ទាប់ នៅឆ្នាំខាងមុខជាបន្ថែមទៀត នៅពេលដែលអត្រាព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ដល់អ្នកផ្ទុកមេរោគអេដស៍ និង ជំងឺអេដស៍ ដែលកំពុងត្រូវការ គឺមានរហូតដល់ទៅជាង៩០% ។ អត្រានេះនឹងឈានទៅដល់១០០% នៅក្នុងឆ្នាំខាងមុខនេះ ដែលបញ្ជាក់ថា លទ្ធផលអត្រាមរណភាពដោយសារជំងឺអេដស៍ ក៏នឹងធ្លាក់ចុះជារៀងរាល់ឆ្នាំតទៅទៀត ។

ឯកឧត្តម លោកជំទាវ លោក-លោកស្រី និងក្មួយៗ ជាទីរាប់អាន!

ទោះបីប្រទេសកម្ពុជារបស់យើង ទទួលបាននូវជោគជ័យដ៏គួរឲ្យកត់សម្គាល់ក៏ពិតមែន ក៏ស្ថានភាពជោគជ័យរបស់យើងនាពេលនេះ នៅមានលក្ខណៈផុយស្រួយណាស់ មានន័យថា ប្រសិនបើធ្វេសប្រហែស នោះការរាលដាលមេរោគអេដស៍ នឹងអាចផ្ទុះឡើងវិញ ដែលពិបាកនឹងធ្វើការគ្រប់គ្រងជាងពេលមុនៗ ជាពិសេស គឺការផ្ទុះឡើងនៅក្នុងចំណោមក្រុមបុរសស្រឡាញ់បុរស ក្រុមអ្នកប្រើប្រាស់ និងចាក់គ្រឿងញៀន ក្រុមយុវវ័យ ។ល។

អាស្រ័យហេតុនេះ យើងត្រូវធ្វើឲ្យចេរភាពនៃជោគជ័យ ដែលយើងទទួលបាន នៅពេលនេះកើតឡើងជាដាច់ខាត ដើម្បីបន្តឈានទៅសំរេចឲ្យបាន នូវគោលដៅបីសូន្យនាឆ្នាំ២០២០ ជាបន្ថែមទៀត តាមរយៈការបន្តនូវការទទួលខុសត្រូវ និង ការចូលរួមទូលំទូលាយតាមបែបពហុវិស័យ ពីស្ថាប័នរដ្ឋាភិបាល ស្ថាប័នឯកជន សង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ បណ្តាញអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ បណ្តាញអ្នកប្រឈមមុខខ្ពស់ នឹងការចម្លង

មេរោគអេដស៍។ល។ ក្រោមការដឹកនាំប្រកបដោយការប្តេជ្ញាចិត្តខ្ពស់របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។

សម្រាប់ការងារនាពេលខាងមុខ កម្ពុជាមានគំរោងផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និង ពហុវិស័យឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍ និង ជំងឺអេដស៍លើកទីបី សម្រាប់ឆ្នាំ២០១១-២០១៣ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។ អ្វីដែលនៅសល់គឺការប្តេជ្ញាចិត្តរបស់យើងទាំងអស់គ្នា ឲ្យបានទ្រទ្រង់ នូវភាពជាម្ចាស់ការ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្នុងការបន្តនូវបេសកកម្មដ៏ថ្លៃថ្លានេះ ក្នុងនាមជាស្ថាប័នដឹកនាំ គ្រប់គ្រង សម្របសម្រួលជាតិ ជំនួសមុខឲ្យរាជរដ្ឋាភិបាល ក្នុងការតាមដាននូវការរាលដាលមេរោគអេដស៍ និងការឆ្លើយតបទៅនឹងជំងឺអេដស៍ សមស្របទៅតាមគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល និងប្រកបដោយសុខដុមនីយកម្មជាមួយដៃគូអភិវឌ្ឍន៍ទាំងអស់ ជាពិសេស គឺការគ្រប់គ្រងការប្រើប្រាស់ធនធានឲ្យបានចំគោលដៅ តាមអាទិភាព ដូចដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រ ដោយធានាឲ្យបាននូវការកសាងទំនុកចិត្ត និង អភិបាលកិច្ចល្អ ក្នុងការឆ្លើយតបរួមគ្នា ទៅនឹងការរាលដាលមេរោគអេដស៍ ។

ឯកឧត្តម លោកជំទាវ លោក-លោកស្រី និងក្មួយៗ ជាទីរាប់អាន!

របៀបវារៈនៃការប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ ដើម្បីឈានទៅសំរេចបាន នូវគោលដៅអភិវឌ្ឍន៍សហស្សវត្ស និង គោលដៅបីសូន្យនាឆ្នាំ២០១៥-២០២០ គឺមិនមែនជាការងាយស្រួលនោះទេ តែក៏មិនមែនមានន័យថា ធ្វើមិនបាននោះដែរ គ្រាន់តែទាមទារនូវការដឹកនាំ និងការចូលរួមប្រកបដោយការប្តេជ្ញាចិត្តមោះមុត និង ជំនះឲ្យបាននូវរាល់ឧបសគ្គនានាដែលរារាំងដល់ការធ្វើអន្តរាគមន៍របស់យើង ដូចជាកត្តាររើសអើង កត្តាធនធាន កត្តាបច្ចេកវិជ្ជា ។ល។

ក្នុងនាមជានាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំសូមប្រកាសជាឱឡារិកថា យុទ្ធនាការប្រយុទ្ធនឹងជំងឺអេដស៍ នៅតែជាអាទិភាពខ្ពស់របស់រាជរដ្ឋាភិបាល ដូចមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល ជាពិសេស គឺការបន្តនូវបេសកកម្មរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលជាស្ថាប័នកំពូលមួយ ជំនួសមុខឲ្យរាជរដ្ឋាភិបាលកម្ពុជាក្នុងការដឹកនាំ គ្រប់គ្រង និង សម្របសម្រួល ការឆ្លើយតបទូលំទូលាយ និង ពហុវិស័យឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ និង ឈានទៅសំរេចឲ្យបានជាដាច់ខាត នូវគោលដៅអភិវឌ្ឍន៍សហស្សវត្ស និង គោលដៅបីសូន្យ ។ ដោយឡែក រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តពិនិត្យលទ្ធភាពក្នុងការបង្កើន នូវធនធានថវិកាជាតិ ឲ្យបានកាន់តែច្រើនថែមទៀត ដើម្បីបំពេញសេចក្តីត្រូវការចាំបាច់ ក្នុងការពង្រីកអត្រាគ្របដណ្តប់ទៅលើភូមិសាស្ត្រ ទៅលើក្រុមគោលដៅ និង ទៅលើសេវាឲ្យបានគ្រប់ជ្រុងជ្រោយ និង ឲ្យបានលឿនតាមដែលអាចធ្វើទៅបាន ។

ឆ្លៀតឱកាសនេះ ខ្ញុំក៏សូមធ្វើការអំពាវនាវផងដែរ ដល់ស្ថាប័នឯកជន សង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ បណ្តាញអ្នកផ្ទុកមេរោគអេដស៍ និង ជំងឺអេដស៍ បណ្តាញអ្នកប្រឈមមុខខ្ពស់នឹងការចម្លងមេរោគអេដស៍ ។ល។ សូមបន្តការចូលរួមឲ្យបានសកម្មថែមទៀត ទៅតាមលទ្ធភាព និង ជំនាញរបស់ខ្លួន ព្រោះថា មានតែការរួមគ្នាទេ ដែលអាចដឹកនាំឲ្យមានការផ្លាស់ប្តូរសង្គមកម្ពុជាយើង ឲ្យចាកផុតពីការគំរាមកំហែងនៃជំងឺអេដស៍ ។

មុននឹងបញ្ចប់ ឆ្លៀតក្នុងឱកាសប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍០១ធ្នូ ឆ្នាំ ២០១៣នេះ ខ្ញុំសូមផ្ញើជូនដល់អង្គពិធីទាំងមូល នូវអនុសាសន៍មួយចំនួន ដូចខាងក្រោម៖

១. សកម្មជនប្រយុទ្ធនឹងជំងឺអេដស៍ទាំងអស់ ត្រូវយកឱកាសដ៏មានតម្លៃនាថ្ងៃនេះ ដោយប្រើប្រាស់គ្រប់រូបភាពទាំងអស់ ធ្វើការផ្សព្វផ្សាយនូវព័ត៌មានថ្មីៗ ស្តីពីការរាលដាលមេរោគអេដស៍ និង ជំងឺអេដស៍ និង លើកទឹកចិត្តប្រជាពលរដ្ឋ ឲ្យមានការចូលរួមកាន់តែខ្លាំងក្លាថែមទៀត ក្នុងការបង្ការ ថែទាំ ព្យាបាល និង គាំទ្រដល់អ្នកផ្ទុកមេរោគអេដស៍ និង ជំងឺអេដស៍ ដើម្បីឈានទៅសម្រេចបាន នូវគោលដៅអភិវឌ្ឍន៍សហស្សវត្ស និង គោលដៅបីសូន្យនាឆ្នាំ២០១៥ ។

២. ត្រូវយកចិត្តទុកដាក់ គ្រប់គ្រងឲ្យបានទ្វេដង នូវការកាត់បន្ថយ ការចម្លងមេរោគអេដស៍ ក្នុងចំណោមក្រុមដែលប្រឈមមុខខ្ពស់ នឹងការចម្លងមេរោគអេដស៍ ជាពិសេស ក្រុមបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ ក្រុមបុរសស្រឡាញ់បុរស ក្រុមអ្នកប្រើគ្រឿងញៀន ។ល។ តាមរយៈវិធានការប្រើប្រាស់ស្រោមអនាម័យ ១០០% ការត្រួតពិនិត្យជំងឺកាមរោគ ការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ ឲ្យបានជាប្រចាំ ការប្រើប្រាស់ម្ជុល សេរាំងដែលស្អាតគ្មានមេរោគ ។ល។ ឲ្យបានខ្ជាប់ខ្ជួន។

៣. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួងសុខាភិបាល កាកបាទក្រហមកម្ពុជា និង ស្ថាប័នពាក់ព័ន្ធ ត្រូវស្វែងរកនូវយុទ្ធសាស្ត្រ គោលនយោបាយ អន្តរាគមន៍ដែលមានប្រសិទ្ធភាពខ្ពស់ ក្នុងការឈានទៅសំរេចឲ្យបាន នូវការកាត់ផ្តាច់ទាំងស្រុង ការចម្លងមេរោគអេដស៍ពីម្តាយទៅកូន នៅឆ្នាំ២០១៥។

៤. ថ្នាក់ដឹកនាំស្ថាប័ន នៅគ្រប់លំដាប់ថ្នាក់ទាំងអស់ ត្រូវយកបញ្ហាអេដស៍ជាអាទិភាព ក្នុងការបញ្ជ្រាប និង បញ្ចូលទៅគ្រប់សេវាទាំងអស់នៅក្នុងស្ថាប័ន និង សហគមន៍របស់ខ្លួន ដើម្បីធានាថា មន្ត្រី បុគ្គលិក ប្រជាជនរបស់ខ្លួន មានចំណេះដឹងត្រឹមត្រូវ និង មធ្យោបាយគ្រប់គ្រាន់ ក្នុងការបង្ការខ្លួន ពីការចម្លងមេរោគអេដស៍ ។

៥. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវបន្តការលើកកម្ពស់សមត្ថភាព ជាអ្នកដឹកនាំល្អ និងជាអ្នកដឹកនាំគំរូ ក្នុងការប្រយុទ្ធនឹងជំងឺអេដស៍ ទៅគ្រប់លំដាប់ថ្នាក់ទាំងអស់ ។

៦. ស្រោមអនាម័យ គឺនៅតែជាអាវុធដ៏មានប្រសិទ្ធភាពខ្ពស់បំផុត ក្នុងការទប់ស្កាត់ការចម្លងមេរោគអេដស៍នៅកម្ពុជា អាស្រ័យហេតុនេះ ត្រូវធ្វើយ៉ាងណា ឲ្យវត្តមានស្រោមអនាម័យមាននៅគ្រប់ទីកន្លែង គ្រប់ពេលវេលាដែលត្រូវការ ប្រកបដោយគុណភាព និង ក្នុងតម្លៃមួយដែលប្រជាពលរដ្ឋអាចទទួលយកបាន ។

៧. កាត់បន្ថយជាបន្ថែមទៀត ដើម្បីឈានទៅលុបបំបាត់ទាំងស្រុង នូវការរើសអើង និង មាក់ងាយដល់អ្នកផ្ទុកមេរោគអេដស៍ និង អ្នកជំងឺអេដស៍ តាមគ្រប់រូបភាពទាំងអស់ ជាពិសេស ពង្រឹងឲ្យបានខ្លាំងក្លា និង ទូលំទូលាយ នូវការអនុវត្តច្បាប់ ស្តីពីការត្រួតពិនិត្យ និង បង្ការការរីករាលដាលមេរោគអេដស៍ និង ជំងឺអេដស៍នៅកម្ពុជា ។

៨. រាល់ការងារប្រយុទ្ធនឹងជំងឺអេដស៍ទាំងអស់ ត្រូវបន្តការឆ្លើយតប ឲ្យបានទូលំទូលាយ និង ពហុវិស័យ ដោយឈរលើគោលការណ៍ គោរពសិទ្ធិមនុស្ស និង សមភាពយេនឌ័រ។

ឯកឧត្តម លោកជំទាវ លោក.លោកស្រី និង ក្មួយៗ ជាទីរាប់អាន!

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរ ជូនអង្គពិធីទាំងមូល នូវពុទ្ធពរទាំបួនប្រការ គឺៈ អាយុ វណ្ណៈ សុខៈ ពលៈ និង សូមសម្រេចបានជោគជ័យថ្មីៗបន្ថែមទៀត ជូនជាតិ មាតុភូមិ នាឆ្នាំខាងមុខនេះ។ ខ្ញុំសូមប្រកាសជាឱឡារិកថា**“កម្ពុជាប្តេជ្ញាធ្វើដំណើរ ឆ្ពោះទៅរកការកាត់ផ្តាច់ទាំងស្រុង នូវការចម្លងមេរោគអេដស៍ពីម្តាយទៅកូន នៅឆ្នាំ២០១៥”**

សូមអរគុណ